

## ជំហានបន្ទាប់

ការធ្វើបច្ចុប្បន្នភាព និងការកែសម្រួល យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ស្តីពីជីវៈចម្រុះ គឺជាដំណើរការគន្លឹះមួយ ក្នុងការបំពេញការប្តេជ្ញាចិត្តរបស់ប្រទេសជាតិដើម្បីឈានឆ្ពោះទៅរកការសម្រេចបាននូវការអនុវត្តន៍គោលបំណងទាំងបី របស់អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ។ គោលបំណងទាំងបីនេះរួមមាន៖ ការអភិរក្ស ធនធានជីវៈចម្រុះ ការប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយនិរន្តរភាព និងការបែងចែកផលប្រយោជន៍ ដែលកើតឡើងពីការប្រើប្រាស់ធនធានសេនេទិចដោយស្មើភាព និងសមធម៌។ ជាការឆ្លើយតបចំពោះកិច្ចខិតខំប្រឹងប្រែងនេះ ក្រសួងបរិស្ថាន បានជម្រុញស្ថាប័នពាក់ព័ន្ធនានា សហគមន៍មូលដ្ឋាន-ជនជាតិដើមភាគតិចម្ចាស់ជំនួយ និងដៃគូអភិរក្សជាតិ-អន្តរជាតិ ឲ្យចូលរួមយ៉ាងពេញទំហឹង ក្នុងដំណើរការធ្វើបច្ចុប្បន្នភាព និងការកែសម្រួល យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះនេះ។

នាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ នៃ អ.ក.ធ
លេខ ៤៨ វុក្ខវិថីព្រះសីហនុ ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ







# គោលដៅ និង សូចនាករជីវៈចម្រុះជាតិ

ជីវៈចម្រុះបង្ហាញពីមុខងាររបស់ប្រព័ន្ធអេកូឡូស៊ី និងការផ្តល់សេវាកម្មរបស់ប្រព័ន្ធអេកូឡូស៊ីដែលមានសារៈខាន់សម្រាប់មនុស្ស។ វាផ្តល់សុវត្ថិភាពស្បៀង សុខភាពមនុស្ស ទឹកស្អាត ខ្យល់បរិសុទ្ធ ចំណីអាហារ និងរួមចំណែកទ្រទ្រង់ដល់ជីវភាពរស់នៅមូលដ្ឋាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយវាមានសារៈសំខាន់សម្រាប់ការសម្រេចនូវគោលដៅអភិវឌ្ឍសហស្សវត្ស៍ ការអភិវឌ្ឍន៍សេដ្ឋកិច្ច រួមទាំងការកាត់បន្ថយភាពក្រីក្រ។

